ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៯៧៨ ◎ ៨៥៩

ក្រសួងមហាផ្ទៃ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០០២

ប្រកាសអន្តរក្រសួង

ស្តីពី

ការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ

៯៧៨ ◎ ៨៥៩

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត-ក្រុង

សម្រេច

ប្រការ១.- អាករសម្រាប់ការបំភ្លឺសាធារណៈ ត្រូវប្រមូលចំនួន ៣ ភាគរយ លើតម្លៃសុរាមេរ៉ៃ ឌឹងបារី ដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ ។

ត្រូវជាប់អាករនេះផងដែរ ចំពោះការដកយក សុរាមេរ៉ៃ និងបារី សម្រាប់តម្រូវការផ្ទាល់ខ្លួនរបស់បុគ្គលជាប់អាករ របស់បុគ្គលិក ឬសម្រាប់តតិយជន។

ប្រការ២.- ត្រូវបានចាត់ជា សុរាមេរ៉ៃ និងបារី ដែលត្រូវជាប់អាករតាមប្រការ១ ខាងលើរួមមាន :

- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិសុរា
- ស្រាវ៉ែមុត និង ស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិ និង សារជាតិក្រអូប
- ភេសជ្ជៈមេរ៉ៃផ្សេងទៀត លើកលែងតែទឹកឆ្ពោតជូរ និងស្រាស
- អាល់កុលអេទីលិកសុទ្ធដែលមានភាគរយជាតិសុរាក្នុងឯកតាចំណុះពី ៨០% នៃចំណុះ ឬលើសពីនេះ និងអាល់កុលអេទីលិក ហើយនិងភេសជ្ជៈមានជាតិសុរាដែលបាត់បង់ភាគរយសុរាដើមរបស់វា
- អាល់កុលអេទីលិកបាត់បង់ជាតុសុទ្ធដែលមានភាគរយជាតិសុរាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈ មានជាតិសុរា ភេសជ្ជៈស្រវឹងផ្សេងៗទៀត តារាងរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេសជ្ជៈ
- បារី ប៊ារីស៊ីហ្គា គ្រប់ប្រភេទ ។

ប្រការ៣.- អាករនេះត្រូវកំណត់នៅគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាករ រួមបញ្ចូលទាំងពន្ធអាកនានា លើកលែងតែអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង និងអាករលើតម្លៃបន្ថែមចំពោះបុគ្គលជាប់អាករតាមរបបពិត ឬអាករលើផលរបរចំពោះបុគ្គលជាប់អាករតាមរបបម៉ៅការ ។

អាករសម្រាប់បំភ្លឺសាធារណៈនេះ ត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់ ។

វិធានកំណត់ពេលផ្គត់ផ្គង់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិចែងសម្រាប់អាករលើតម្លៃបន្ថែម និងអាករលើផលរបរ ។

ប្រការ៤.- បុគ្គលដែលធ្វើការផ្គត់ផ្គង់ សុរាមេរ៉ៃ និងបារី គឺជាបុគ្គលជាប់អាករសម្រាប់បំភ្លឺសាធារណៈ និងត្រូវទទួលខុសត្រូវបង់ប្រាក់អាកនេះ។

ដើម្បីគណនាប្រាក់អាកត្រូវបង់ បុគ្គលជាប់អាកត្រូវធ្វើការបែងចែកឱ្យបានរាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ៉ៃ និងបារី ជាប់អាករ និងផលរបរបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដ៍ទៃទៀត ។

ក្នុងករណីដែលបុគ្គលជាប់អាករតាមរបបម៉ៅការពុំអាចធ្វើការបែងចែកផលរបរបាន មន្ត្រីពន្ធត្រូវពិភាក្សាជាមួយបុគ្គលជាប់អាករ ដើម្បីកំណត់សមាមាត្រនៃផលរបរបានមកពីការផ្គត់ផ្គង់ សុរាមេរ៉ៃ និងបារី ជាប់អាករ ។ សមាមាត្រនេះត្រូវបានពិនិត្យ និងសម្រេច ដោយប្រធានសាខាពន្ធដារខេត្ត-ក្រុង ។

ប្រការ៥.- បុគ្គលជាប់អាករតាមរបបពិត ត្រូវដាក់លិខិតប្រចាំខែ យ៉ាងយឺតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ហើយត្រូវបង់ប្រាក់អាករនេះទៅតាមចំនួនដែលបានប្រកាស នៅពេលដាក់លិខិតប្រកាសនោះ ។

បុគ្គលជាប់អាករតាមរបបម៉ៅការ ត្រូវបង់ប្រាក់អាកនេះជារៀងរាល់ខែ យ៉ាងយឺតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ ។

បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដែលចែងក្នុងច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រូវយកមកអនុវត្តចំពោះអាករសម្រាប់បំភ្លឺសាធារណៈនេះ ។

ប្រការ៦.- អង្គការមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈនេះត្រូវបានកំណត់ដូចខាងក្រោម :

- ការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិត មានភារកិច្ចប្រមូលអាកនេះ ចំពោះបុគ្គលជាប់អាករតាមរបបពិត ។

- សាខាពាណិជ្ជកម្មខេត្ត-ក្រុង មានការកិច្ចប្រមូលអាករនេះ ចំពោះបុគ្គលជាប់អាករតាមបែបមៅការនៅក្នុង មណ្ឌលដែនដីខេត្ត-ក្រុងរបស់ខ្លួន ។
- ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុងកែប អភិបាលគ្រប់ខេត្ត-ក្រុង មានសិទ្ធិតាមដានជំរុញនូវការប្រមូលចំណូលទាំងនោះ ។

ប្រការ៧.- ប្រាក់ចំណូលបានមកពីការប្រមូលអាករនេះ ត្រូវបានជាប្រយោជន៍ថវិកាខេត្ត-ក្រុង ទុកសម្រាប់ចំណាយឱ្យការបំភ្លឺសាធារណៈ ។

ប្រការ៨.- អគ្គនាយករដ្ឋបាល នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ ក្រុងប៉ៃលិន ក្រុបកែប អភិបាលគ្រប់ខេត្ត-ក្រុង ប្រធាននាយកដ្ឋានពន្ធដារ និង ប្រធាននាយកដ្ឋានធនាគារចំណុះឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ។

ប្រការ៩.- ប្រការនេះមានប្រសិទ្ធិភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

សហរដ្ឋមន្ត្រី
ក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាលកម្ពុជា

ស ខេង

ចម្លងជូន :
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន
  ដើម្បីជូនជ្រាប
- ដូចប្រការ ៨ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ ។